ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

ការកំណត់ទីតាំង
មណ្ឌលថែទាំជំនួស

ខែមីនា ឆ្នាំ២០១៦

រាជធានីភ្នំពេញ | ខេត្តសៀមរាប | ខេត្តបាត់ដំបង | ខេត្តកណ្ដាល | ខេត្តព្រះសីហនុ

រៀបចំ និង រចនា ៖ © ណូវ៉ា (ខេមបូឌា)/២០១៦

រាល់ការផលិតឡើងវិញនូវផ្នែកណាមួយនៃរបាយការណ៍នេះ
ចាំបាច់ត្រូវមានការអនុញ្ញាត។

សូមទាក់ទង ៖
ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
អាសយដ្ឋាន ៖ អគារលេខ ៧៨៨ មហាវិថីព្រះមុនីវង្ស
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
លេខទូរស័ព្ទ ៖ (+៨៥៥) ២៣ ២១៤ ០៣៩
អ៊ីម៉ែល ៖ mosvy.cwd@gmail.com
គេហទំព័រ ៖ mosvy.gov.kh
រាជធានីភ្នំពេញ ខែ មិនា ឆ្នាំ២០១៦

ការកំណត់ទីតាំង
មណ្ឌលថែទាំជំនួស

ខែមីនា ឆ្នាំ២០១៦



រាជធានីភ្នំពេញ | ខេត្តសៀមរាប | ខេត្តបាត់ដំបង | ខេត្តកណ្ដាល | ខេត្តព្រះសីហនុ [1]

[1] *ភ្នំពេញ គឺជារាជធានី ពុំមែនជាខេត្តទេ ប៉ុន្តែសម្រាប់គោលបំណងនៃរបាយការណ៍នេះ ពាក្យថា ខេត្ត ក៏រាប់បញ្ចូលរាជធានីភ្នំពេញផងដែរ។*

អារម្ភកថា

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រៀបចំផ្សព្វផ្សាយរបាយការណ៍បឋមស្តីពីការកំណត់ទីតាំងមណ្ឌលថែទាំជំនួសចំពោះកុមារ។ ការកំណត់ទីតាំងមណ្ឌលថែទាំជំនួសនេះចាប់ផ្តើមនៅចន្លោះខែវិច្ឆិកា ឆ្នាំ២០១៤ និងខែកុម្ភៈ ឆ្នាំ២០១៥ នៅរាជធានី ខេត្តអាទិភាពទាំងប្រាំ គឺរាជធានីភ្នំពេញ ខេត្តសៀមរាប បាត់ដំបង កណ្តាល និងខេត្តព្រះសីហនុ។

គោលបំណងនៃការកំណត់ទីតាំងមណ្ឌលថែទាំជំនួសនេះ គឺដើម្បីកំណត់អត្តសញ្ញាណមណ្ឌលថែទាំជំនួស រួមទាំងមណ្ឌលមិនទាន់បានចុះបញ្ជីជាមួយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងធ្វើការប្រមូលព័ត៌មានមូលដ្ឋានអំពីប្រភេទមណ្ឌលថែទាំជំនួស និងចំនួនកុមារដែលកំពុងរស់នៅក្នុងមណ្ឌលទាំងនោះ។ ចំពោះមណ្ឌលដែលបានរកឃើញថ្មីនឹងត្រូវបញ្ចូលទៅក្នុងបញ្ជីអធិការកិច្ចប្រចាំឆ្នាំរបស់ក្រសួង ហើយមណ្ឌលទាំងនោះត្រូវដាក់ពាក្យស្នើសុំការអនុញ្ញាតដើម្បីបន្តកិច្ចប្រតិបត្តិការមកក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទានៅឆ្នាំ២០១៦។

ការកំណត់ទីតាំងមណ្ឌលថែទាំជំនួសនេះបានរកឃើញទិន្នន័យបឋមមានមណ្ឌលចំនួន ៤០១ ដែលកំពុងដំណើរការផ្តល់សេវាថែទាំជំនួសដល់កុមារនៅក្នុងប្រាំខេត្តដែលមានកុមារសរុបចំនួន១៨.៤៥១នាក់។ បន្ថែមពីលើនេះមានយុវវ័យចំនួន ៧.៧០៨នាក់ (៣៥% ជាស្ត្រី)ដែលមានអាយុលើសពី ១៨ ឆ្នាំ កំពុងរស់នៅក្នុងកន្លែងថែទាំទាំងនោះ។ ក្នុងនោះមានតែ ២៦៧ មណ្ឌលដែលមានលក្ខណៈសមស្របតាមនិយមន័យនៃបទដ្ឋានស្តីពីការថែទាំជំនួសចំពោះកុមារ។ មានកុមារអាយុក្រោម ១៨ ឆ្នាំ សរុបចំនួន ១១.៧៨៨នាក់ ដែលកំពុងរស់នៅក្នុងមណ្ឌលទាំង ២៦៧ នេះ ក្នុងនោះកុមារីមានចំនួន ៥.៦០៧នាក់ (៤៨%) និងកុមារាមានចំនួន ៦.១៨១នាក់(៥២%)។ក្រៅពីនេះគឺជាកន្លែងថែទាំដទៃទៀត ដូចជា ផ្ទះស្នាក់នៅបណ្តោះអាសន្ន កន្លែងស្នាក់នៅបណ្តោះអាសន្ន ផ្ទះស្នាក់នៅជាក្រុម វត្តអារាម និងការថែទាំនៅក្នុងអគារសាសនា និងអន្តេវាសិកដ្ឋាន។

ដោយមានការគាំទ្រថវិកាបន្ថែមពីទីភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិសហរដ្ឋអាមេរិក និងអង្គការយូនីសេហ្វ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា បានកំណត់ទីតាំងមណ្ឌលថែទាំកុមារនៅ ២០ខេត្ត បន្ថែមទៀតពីខែតុលា ដល់ខែធ្នូ ឆ្នាំ២០១៥។ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទានឹងចេញផ្សាយរបាយការណ៍ស្តីពីការកំណត់ទីតាំងមណ្ឌលគ្រប់រាជធានី ខេត្តទាំងអស់នៅពាក់កណ្តាលឆ្នាំ២០១៦ ដែលរួមបញ្ចូលទាំងការវិភាគទិន្នន័យបន្ថែម និងអនុសាសន៍នានាដើម្បីពង្រឹងប្រព័ន្ធថែទាំជំនួសចំពោះកុមារ ដោយផ្អែកលើការរកឃើញចំណុចគន្លឹះនៅខេត្តទាំង២៥។ ក្នុងន័យនេះក្រសួង សូមស្វាគមន៍ និងទទួលស្គាល់នូវរបកគំហើញក្នុងរបាយការណ៍នេះ ហើយប្តេជ្ញាចាត់វិធានការបន្ថែមទៀតដើម្បីអនុវត្តសកម្មភាពចាំបាច់នានាជាមួយដៃគូរ ក្រសួង ស្ថាប័នពាក់ព័ន្ធ អង្គការសង្គមស៊ីវិល ព្រមទាំងប្រធានមណ្ឌលថែទាំកុមារ និងអាជ្ញាធរពាក់ព័ន្ធនានា ដើម្បីពិនិត្យ និងពង្រឹងការអនុវត្តគោលនយោបាយ ក្របខ័ណ្ឌច្បាប់ ដែលមានស្រាប់ដើម្បីសមាហរណកម្មកុមាររស់នៅក្នុងមណ្ឌលថែទាំកុមារនៅក្នុងរាជធានី ខេត្តទាំងប្រាំឲ្យបាន ៣០% នៅឆ្នាំ២០១៨។ ក្រសួងប្តេជ្ញាអនុវត្តគោលការណ៍មិនធ្វើឱ្យមានហានិភ័យដល់កុមារ និងឈរលើឧត្តមប្រយោជន៍របស់កុមារនូវរាល់ការសម្រេចចិត្តផ្សេងៗពាក់ព័ន្ធនឹងកុមារ។

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់ ក្រសួង ស្ថាប័ន អាជ្ញាធរពាក់ព័ន្ធនានា ជាពិសេសមន្ត្រីនាយកដ្ឋានសុខុមាលភាពកុមារ មន្ត្រីមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទារាជធានីខេត្ត មន្ត្រីការិយាល័យសង្គមកិច្ច អតីតយុទ្ធជន និងវយុវនីតិសម្បទាក្រុង ស្រុក ខណ្ឌ អង្គការយូនីសេហ្វ អាជ្ញាធរមីនកម្ពុជា គម្រោងភាពជាដៃគូដើម្បីកិច្ចការពារកុមារ (3PC) ដែលបានផ្តល់ការគាំទ្រផ្នែកបច្ចេកទេសដល់ការកំណត់ទីតាំងមណ្ឌលនេះ។ ក្រសួងសូមថ្លែងអំណរគុណជាពិសេសចំពោះទីភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិសហរដ្ឋអាមេរិក ដែលបានផ្តល់ការគាំទ្រដល់ដំណើរការធ្វើឲ្យប្រសើរឡើងលើការថែទាំកុមារនៅកម្ពុជា។

ជាទីបញ្ចប់ ខ្ញុំសូមបញ្ជាក់ជាថ្មីម្តងទៀតថា ការកំណត់ទីតាំងនេះគឺជាបទពិសោធន៍ដំបូង ដូច្នេះខ្ញុំជឿជាក់ថាព័ត៌មានមួយចំនួននៅមិនទាន់បានប្រមូលគ្រប់ជ្រុងជ្រោយនូវឡើយ។ សូមជំរាបជូនថាទិន្នន័យដែលទទួលបាននេះគឺ ជាការរាយការណ៍ដោយផ្ទាល់ពីមណ្ឌលនីមួយៗ ហើយមិនមានការបញ្ជាក់ឡើងវិញពីអ្នកប្រមូលទិន្នន័យទេ។ ហេតុនេះ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនិតិសម្បទា សូមស្វាគមន៍ចំពោះមតិយោបល់ស្ថាបនាពីគ្រប់ដៃគូពាក់ព័ន្ធនានាដើម្បីធ្វើឲ្យប្រសើរឡើងក្នុងការប្រមូលទិន្នន័យនាពេលអនាគត និងប្រើប្រាស់ទិន្នន័យនេះឲ្យមានប្រសិទ្ធភាពខ្ពស់។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១៩ខែមិនា ឆ្នាំ២០១៦

រដ្ឋមន្ត្រី

វង សូត

១.០ សេចក្តីផ្តើម និង វិសាលភាពនៃរបាយការណ៍

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាបានចុះកំណត់ទីតាំងកន្លែងថែទាំជំនួសចំពោះកុមារដើម្បីស្រង់ព័ត៌មានខ្វះចន្លោះអំពីចំនួនមណ្ឌលផ្តល់សេវាថែទាំជំនួសចំពោះកុមារ។ ព័ត៌មានដែលមានបច្ចុប្បន្នគឺ តាមរយៈការធ្វើអធិការកិច្ចរបស់ក្រសួង។ ព័ត៌មានទាំងនេះមិនបានរួមបញ្ចូលមណ្ឌលថែទាំជំនួសចំពោះកុមារដែលមិនបានចុះកិច្ចព្រមព្រៀងជាមួយក្រសួង។ តាមការសន្និដ្ឋានមានមណ្ឌលថែទាំជំនួសចំពោះកុមារយ៉ាងច្រើននៅប្រទេសកម្ពុជា ហើយការកំណត់ទីតាំងមណ្ឌលនេះ ជាវិធីសាស្ត្រដ៏មានប្រសិទ្ធិភាពមួយក្នុងការកំណត់អត្តសញ្ញាណមណ្ឌលទាំងនោះ។

ទិន្នន័យសំខាន់ៗ អំពីចំនួនមណ្ឌលនៅក្នុងរាជធានី ខេត្តគោលដៅទាំងប្រាំ (រាជធានីភ្នំពេញ ខេត្តសៀមរាប បាត់ដំបង កណ្តាល និងខេត្តព្រះសីហនុ) ផ្តល់នូវប្រភេទខុសគ្នានៃកន្លែងថែទាំកុមារ និងចំនួនកុមារ ដែលកំពុងស្នាក់នៅក្នុងមណ្ឌល។ ក្រសួងមានការជឿជាក់លើទិន្នន័យដែលប្រមូលបានដោយការកំណត់អត្តសញ្ញាណមណ្ឌលថែទាំកុមារនៅរាជធានីខេត្តគោលដៅទាំងប្រាំពីព្រោះមានការចូលរួមសម្របសម្រួលពីប្រធានភូមិ និងគណៈកម្មាធិការស្ត្រី និងកុមារឃុំសង្កាត់ និងការចុះពិនិត្យផ្ទាល់ដោយមន្ត្រីប្រមូលទិន្នន័យ។ ទិន្នន័យដែលមាននៅក្នុងរបាយការណ៍នេះបានមកពីការរាយការណ៍របស់មណ្ឌលដោយផ្ទាល់ តែមិនបានត្រួតពិនិត្យឡើងវិញដោយអ្នកប្រមូលទិន្នន័យឡើយ។

បទពិសោធន៍ដែលទទួលបានពីការកំណត់ទីតាំងមណ្ឌលថែទាំជំនួសចំពោះកុមារក្នុងរាជធានី ខេត្តទាំងប្រាំនេះបានយកមកពង្រឹងគុណភាពក្នុងការអនុវត្តនៅខេត្តចំនួន២០ទៀតដែលនៅសល់ ហើយបានបញ្ចប់នៅខែធ្នូ ឆ្នាំ២០១៥។ ក្រសួងនឹងផ្សព្វផ្សាយរបាយការណ៍ទាំងស្រុងស្តីពីការកំណត់ទីតាំងមណ្ឌលថែទាំជំនួសចំពោះកុមារនៅពាក់កណ្តាលឆ្នាំ២០១៦ ដែលនឹងបញ្ចូលការវិភាគទិន្នន័យ និងអនុសាសន៍ដើម្បីពង្រឹងប្រព័ន្ធថែទាំជំនួសចំពោះកុមារ។

របាយការណ៍នេះ គឺមានវិសាលភាពបង្ហាញពីទិន្នន័យបឋមក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់ ក្រសួង ស្ថាប័ន អាជ្ញាធរពាក់ព័ន្ធនានា ជាពិសេសមន្ត្រីនាយកដ្ឋាន សុខុមាលភាពកុមារ មន្ត្រីមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទារាជធានីខេត្ត មន្ត្រីការិយាល័យសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាក្រុង ស្រុក ខណ្ឌ អង្គការយូនីសេហ្វអាជ្ញាធរមីនកម្ពុជា គម្រោងភាពជាដៃគូដើម្បីកិច្ចការពារកុមារ (3PC)[2] ដែលបានផ្តល់ការគាំទ្រផ្នែកបច្ចេកទេសដល់ការកំណត់ទីតាំងមណ្ឌលថែទាំជំនួសចំពោះកុមារនេះ។ ក្រសួងសូមថ្លែងអំណរគុណជាពិសេសចំពោះទីភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិសហរដ្ឋអាមេរិក ដែលបានផ្តល់ការគាំទ្រដល់ដំណើរការធ្វើឲ្យប្រសើរឡើងលើការថែទាំកុមារនៅកម្ពុជា។

[2] កម្មវិធីភាពជាដៃគូរដើម្បីកិច្ចការពារកុមារ (3PC) គឺជាកិច្ចសហប្រតិបត្តិការរវាងក្រសួង ស.អ.យ អង្គការយូនីសេហ្វ និងអង្គការមិត្តសំឡាញ់អន្តរជាតិ។ អង្គការសង្គមស៊ីវិលចំនួន ៩ និងក្រុមគោលដៅសហគមន៍ចំនួន ៤១ គឺស្ថិតនៅក្រោមឆ័ត្ររបស់អង្គការ

២.0 សង្ខេបរបកគំហើញសំខាន់ៗ

មានកន្លែងថែទាំជំនួសចំពោះកុមារចំនួន ៤០១ កំពុងប្រតិបត្តិការនៅក្នុងរាជធានីខេត្តគោលដៅទាំង៥។ ផ្អែកលើសេចក្តីរាយការណ៍ពីបុគ្គលិកមណ្ឌលបានឲ្យដឹងថាមណ្ឌលទាំងនោះអាចចែកជាប្រាំប្រភេទ៖

២៦៧
មណ្ឌលថែទាំកុមារ

២០
កន្លែងស្នាក់នៅបណ្ដោះអាសន្ន

៥៧
ផ្ទះស្នាក់នៅជាក្រុម

១១
វត្តអារាម និងអគារសាសនា

៤៦
អន្តេវាសិកដ្ឋាន

របាយការណ៍នេះផ្តោតលើមណ្ឌលថែទាំជំនួសចំពោះកុមារទាំង ២៦៧ ដែលមាន លក្ខខណ្ឌស្របតាមនិយមន័យនៃបទដ្ឋានមណ្ឌលថែទាំជំនួសចំពោះកុមារដូចមានរៀបរាប់នៅក្នុងឧបសម្ព័ន្ធ១។ មណ្ឌលថែទាំជំនួស ចំពោះកុមារគឺជាកន្លែងរស់នៅជាក្រុមសម្រាប់កុមារដែលត្រូវបានបោះបង់ ឬ មិនអាចរស់នៅជាមួយគ្រួសារបង្កើត និងសាច់ញាតិរបស់ពួកគេនៅក្នុងសហគមន៍ និងត្រូវទទួលបានការថែទាំង និងផ្តល់សេវាពីមនុស្សចាស់។ ក្នុងចំណោមមណ្ឌលថែទាំជំនួសចំពោះកុមារទាំង ២៦៧ មានមណ្ឌលចំនួន ១៧៣ (៦៥%) ផ្តល់ការថែទាំរយៈពេលវែង (លើសពី៦ខែ)។មានមណ្ឌលចំនួន ២៣ (៩%) ផ្តល់ការថែទាំរយៈពេលខ្លី (តិចជាង ៦ខែ) និង មណ្ឌលចំនួន ៧១ (២៦%) ដែលគេមិនដឹងអំពីរយៈពេលអនុញ្ញាតឱ្យស្នាក់នៅក្នុងមណ្ឌល។

មានកុមារអាយុក្រោម១៨ឆ្នាំ សរុបចំនួន១១.៧៨៨ នាក់ ដែលកំពុងរស់នៅក្នុងមណ្ឌលទាំង ២៦៧ ក្នុងនោះកុមារីមានចំនួន៥.៦០៧នាក់(៤៨%)និងកុមារាមានចំនួន៦.១៨១នាក់ (៥២%)។ ស្រដៀងគ្នានេះដែរចំនួនកុមារអាយុក្រោម ១៨ឆ្នាំកំពុងរស់នៅមណ្ឌលទាំង ៤០១ មាន ១៨.៤៥១នាក់ (៤៨% ជាកុមារី)។ បន្ថែមពីលើនេះមានយុវវ័យចំនួន ៧.៧០៨នាក់ (៣៥%ជាស្ត្រី) ដែលមានអាយុលើសពី១៨ឆ្នាំកំពុងរស់នៅក្នុងកន្លែងថែទាំទាំងនោះ។ សរុបទាំងកុមារ និងយុវវ័យមាន ២៦.១៥៩នាក់ (៤៥% ជាស្រី) កំពុងរស់នៅក្នុងកន្លែងថែទាំជំនួសចំពោះកុមារទាំង៤០១ កន្លែង។

៣.០ សាវតា និងបរិបទ

នៅក្នុងរយៈពេលប៉ុន្មានឆ្នាំថ្មីៗនេះ មណ្ឌលថែទាំជំនួសចំពោះកុមារបានកើនឡើងជាលំដាប់នៅប្រទេសកម្ពុជា ហើយកុមារជាច្រើនត្រូវបានបំបែកពីគ្រួសាររបស់ពួកគេ និងត្រូវបានទុកដាក់នៅក្នុងមណ្ឌលដោយមិនចាំបាច់។ កុមារភាគច្រើនដែលកំពុងរស់នៅក្នុងមណ្ឌលថែទាំទាំងនោះ មិនមែនជាកុមារកំព្រា ឬកុមារដែលត្រូវបានគេបោះបង់នោះទេ[3] ប៉ុន្តែពួកគេគឺជាកុមារដែលមកពីគ្រួសារងាយរងគ្រោះ ដែលឪពុកម្តាយ ឬសាច់ញាតិរបស់ពួកគេបានយកទៅដាក់នៅទីនោះដើម្បីសម្រាលបន្ទុកហិរញ្ញវត្ថុ។ ទោះជាយ៉ាងណា មិនមែនគ្រួសារក្រីក្រទាំងអស់បញ្ជូនកូនឲ្យទៅរស់នៅក្នុងមណ្ឌលនោះទេ និងមានកត្តាជាច្រើនទៀតដូចជាឪពុកម្តាយបែកបាក់គ្នាដោយគិតថាមណ្ឌល គឺជាជម្រើសដ៏ល្អសម្រាប់ការថែទាំ ឬសិក្សារៀនសូត្រ និងតាមការឃោសនា និងការជ្រើសរើសពីអ្នកគ្រប់គ្រងមណ្ឌលដែលធ្វើឲ្យគ្រួសារងាយរងគ្រោះសំរេចចិត្តបញ្ជូនកូនពួកគាត់ទៅមណ្ឌល[4]។ ស្ថានភាពនេះមានលក្ខណៈគួរឱ្យព្រួយបារម្ភជាពិសេស អាស្រ័យដោយភស្តុតាងវិទ្យាសាស្ត្របង្ហាញឱ្យដឹងថាការរស់នៅក្នុងមណ្ឌល អាចបង្កឱ្យមានគ្រោះថ្នាក់ទៅលើការអភិវឌ្ឍន៍ផ្នែកសង្គម ផ្លូវកាយ សតិបញ្ញា និងផ្លូវចិត្តរបស់កុមារ ហើយមានផលប៉ះពាល់រយៈពេលវែងនៅក្នុងជីវិតរស់នៅពេលពួកគាត់ក្លាយជាមនុស្សពេញវ័យ កុមារដែលរស់នៅក្នុងមណ្ឌលថែទាំអាចប្រឈមទៅនឹងអំពើរំលោភបំពាន និងអំពើហិង្សាកាន់តែខ្លាំង[5]។

ចាប់តាំងពីឆ្នាំ ២០០៦ មក ក្រសួងបានពង្រឹងក្របខ័ណ្ឌថែទាំជំនួសដើម្បីលើកកម្ពស់ការថែទាំតាមគ្រួសារ និងសហគមន៍ ព្រមទាំងបានរៀបចំលិខិតបទដ្ឋានគតិយុត្តិកាន់តែប្រសើរ ដើម្បីពង្រឹងគុណភាពនៃការថែទាំជំនួស។ បើទោះបីមានកិច្ចខិតខំប្រឹងប្រែងបែបនេះក៏ដោយ ក្រសួងបានត្រឹមតែអាចធ្វើការផ្ទៀងផ្ទាត់ទៅលើការប្រតិបត្តិស្របតាមបទដ្ឋានអប្បបរមានៃការថែទាំជំនួសចំពោះកុមារ នៅក្នុងមណ្ឌលមួយចំនួនតូចប៉ុណ្ណោះ ជាពិសេស គឺមណ្ឌលថែទាំកុមារដែលមានកិច្ចព្រមព្រៀងជាមួយក្រសួង។ បើទោះជាដូច្នេះក្តីបច្ចុប្បន្នមានកុមារជាច្រើនកំពុងទទួលបានការថែទាំ និងសេវាដែលមិនស្របតាមបទដ្ឋាននៃការថែទាំរបស់ក្រសួង មានន័យថា មណ្ឌលទាំងនោះមិនបានដាក់បញ្ចូលក្នុងបញ្ជីត្រួតពិនិត្យរបស់ក្រសួង ដើម្បីធានាថាមានការផ្តល់សេវាដែលប្រកបដោយគុណភាពនោះឡើយ។

ដើម្បីបំពេញការខ្វះចន្លោះនេះ ក្រសួងបានសម្រេចធ្វើការកំណត់ទីតាំងមណ្ឌលនានាដែលមិនមែនជាការថែទាំជាលក្ខណៈគ្រួសារ និងរាប់បញ្ចូលមណ្ឌលដែលមិនបានចុះបញ្ជី និងមណ្ឌលដែលក្រសួងមិនទាន់បានធ្វើអធិការកិច្ច។ ការកំណត់ទីតាំងមណ្ឌលត្រូវបានធ្វើឡើងនៅក្នុងរាជធានីខេត្តគោលដៅទាំង៥ ដែលគេជឿថា អាចរកឃើញមណ្ឌលថែទាំកុមារភាគច្រើន។ រាជធានីខេត្តទាំងនោះ រួមមានរាជធានីភ្នំពេញ ខេត្តសៀមរាប បាត់ដំបង កណ្តាល និងខេត្តព្រះសីហនុ។

ក្រសួងបានអនុវត្តធ្វើការកំណត់ទីតាំងមណ្ឌលនៅចន្លោះខែវិច្ឆិកា ឆ្នាំ២០១៤ និង ខែកុម្ភៈ ឆ្នាំ២០១៥ ដោយមានការគាំទ្រពីអង្គការយូនីសេហ្វ និងគម្រោងភាពជាដៃគូរដើម្បីកិច្ចការពារកុមារ ព្រមទាំងទទួលបានកិច្ចគាំទ្រហិរញ្ញវត្ថុពីមូលនិធិកុមារចំណាកស្រុក និងកុមារកំព្រានៃទីភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិសហរដ្ឋអាមេរិក និងមូលនិធិកុមារកំព្រា។

[3] *ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា មូលដ្ឋានទិន្នន័យអំពីការថែទាំជំនួស។*

[4] *UNICEF, 2011. A study of attitudes towards residential care in Cambodia, UNICEF, Phnom Penh.*

[5] *Bowlby, 1951; Hodges & Tizard, 1989; Johnson et al., 2006; Vorria et al., 1998; Wolkind & Rutter, 1973.*

៩.០ វិធីសាស្ត្រ និងដែនកំណត់

វិធីសាស្ត្រនេះត្រូវបានរៀបចំឡើងដើម្បីបំពេញការខ្វះខាតព័ត៌មានអំពីចំនួនមណ្ឌលថែទាំកុមារនៅក្នុងរាជធានីខេត្តគោលដៅទាំងប្រាំ តាមរយៈការចុះពិនិត្យមណ្ឌលផ្ទាល់ និងបានកំណត់អត្តសញ្ញាណមណ្ឌលថែទាំជំនួសចំពោះកុមារដោយផ្អែកលើចំណេះដឹងរបស់អ្នកផ្តល់ព័ត៌មាន និងការចុះពិនិត្យដោយផ្ទាល់ដល់កន្លែងថែទាំកុមារទាំងនោះ។ ប្រភេទកន្លែងថែទាំមិនមែនជាក្រុមគ្រួសារត្រូវបានចាត់ទុកជាមណ្ឌលថែទាំ កន្លែងស្នាក់នៅបណ្តោះអាសន្ន ផ្ទះរស់នៅជាក្រុម វត្តអារាមនិងអាគារសាសនា និងអន្តេវាសិកដ្ឋាន។ កន្លែងថែទាំកុមារមិនមានបើកប្រាក់ខែដល់បុគ្គលិកមិនរាប់បញ្ចូលឡើយ។ អ្នកផ្តល់ព័ត៌មានរួមមានមេឃុំ មេភូមិ និងសមាជិកគណៈកម្មាធិការទទួលបន្ទុកស្ត្រី និងកុមារដែលជាអ្នកកំណត់ប្រភេទកន្លែងថែទាំកុមារមិនមែនជាការថែទាំលក្ខណៈគ្រួសារផ្អែកតាមការយល់ដឹងរបស់ពួកគាត់នៅក្នុងភូមិឃុំ។ អ្នកប្រមូលទិន្នន័យ ចំនួន ៥១នាក់ ជាមន្ត្រីការិយាល័យសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាក្រុង ស្រុក ខណ្ឌ។ អ្នកប្រមូលទិន្នន័យទាំងនោះបានទទួលការគាំទ្រដោយបុគ្គលិកអង្គការដៃគូ និងគ្រប់គ្រងដោយមន្ត្រីបង្គោលខេត្ត ១០នាក់នៃមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទារាជធានី ខេត្ត និងត្រួតពិនិត្យពីក្រុមការងាររបស់នាយកដ្ឋានសុខុមាលភាពកុមាររបស់ក្រសួង។ មន្ត្រីក្រសួង បុគ្គលិកអង្គការដៃគូគម្រោងកិច្ចការពារកុមារបានរួមគ្នាធ្វើការ បណ្តុះបណ្តាលចំនួនប្រាំពីរថ្ងៃដល់អ្នកប្រមូលទិន្នន័យ និងអ្នកគ្រប់គ្រង។ បន្ទាប់ពីការប្រមូលទិន្នន័យ ទម្រង់សំណួរត្រូវបានត្រួតពិនិត្យ ផ្ទៀងផ្ទាត់កែសម្រួលដោយមន្ត្រីបង្គោលខេត្ត និងបញ្ជូនមកមន្ត្រីក្រសួងមុននឹងបញ្ជូនទៅអាជ្ញាធរមីនកម្ពុជាដើម្បីបញ្ចូលក្នុងប្រព័ន្ធទិន្នន័យ។ អ្នកប្រមូលទិន្នន័យទាំងអស់ត្រូវបញ្ជូនទម្រង់សំណួរដើម្បីឲ្យមេឃុំចុះហត្ថលេខា និងបោះត្រា ដើម្បីបញ្ជាក់ថាពួកគេបានសម្របសម្រួលជាមួយមេឃុំ និងបានចុះដល់ទីកន្លែងថែទាំកុមារពិតប្រាកដមែន។

ទិន្នន័យដែលបានប្រមូលត្រូវបានបញ្ចូល និងវិភាគដោយអាជ្ញាធរមីនកម្ពុជា និងនាយកដ្ឋានសុខុមាលភាពកុមារ នៃក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ដោយមានការគាំទ្របច្ចេកទេសពីបុគ្គលិកអង្គការយូនីសេហ្វ។ ជាថ្មីម្តងទៀត សូមជម្រាបដល់អ្នកអានថា ទិន្នន័យនេះគឺបំពេញតាមការផ្តល់ពត៌មានដោយបុគ្គលិកមណ្ឌលតែមិនមានការត្រួតពិនិត្យ ឬរាប់ចំនួនជាក់ស្តែងនោះទេ ដូចនេះប្រាកដជាមានការខ្វះខាតខ្លះពុំខាន។

ក្រសួងមានការជឿជាក់ថាភាគច្រើននៃកន្លែងថែទាំកុមារនៅក្នុងរាជធានី ខេត្តទាំងប្រាំត្រូវបានរកឃើញតែសូមកត់សំគាល់ថា អ្នកផ្តល់ព័ត៌មានអាចមិនបានដឹងពីកន្លែងថែទាំកុមារដទៃទៀតមាននៅក្នុងតំបន់របស់ពួកគាត់ ជាពិសេសកន្លែងតូចៗ មិនទាន់ជាផ្លូវការ ឬទើបបង្កើតថ្មី។

៥.០ ការបង្ហាញអំពីទិន្នន័យ និងរបកគំហើញសំខាន់ៗ

របាយការណ៍នេះ ត្រូវបានបែងចែកជា៣ផ្នែកតូចៗ គឺផ្នែកទី១ បង្ហាញអំពីចំនួន និងប្រភេទមណ្ឌល ផ្នែកទី២ បង្ហាញអំពីទិន្នន័យមណ្ឌលដែលមានលក្ខខណ្ឌស្របតាមនិយមន័យនៃបទដ្ឋានមណ្ឌលថែទាំកុមារ កំព្រា ឬកុមារដែលត្រូវបានគេបោះបង់ ហើយផ្នែកទី៣ បង្ហាញអំពីទិន្នន័យកន្លែងស្នាក់នៅបណ្តោះអាសន្ន ផ្ទះរស់នៅជាក្រុម វត្តអារាម និងអគារសាសនា និងអន្តេវាសិកដ្ឋាន ហើយមានយុវជនអាយុលើស១៨ឆ្នាំ កំពុងរស់នៅក្នុងកន្លែងថែទាំទាំងនោះ។

៥.១ ចំនួន និងប្រភេទមណ្ឌល

តារាងទី១ ៖ ចំនួន និងប្រភេទមណ្ឌលថែទាំជំនួសចំពោះកុមារ

ប្រភេទមណ្ឌលដែលផ្តល់ការថែទាំសម្រាប់កុមារ	ចំនួនមណ្ឌលដែលផ្តល់ការថែទាំសម្រាប់កុមារ
មណ្ឌលថែទាំកុមារ	២៦៧
កន្លែងស្នាក់នៅបណ្តោះអាសន្ន	២០
ផ្ទះរស់នៅជាក្រុម	៥៧
វត្តអារាម និងអគារសាសនា	១១
អន្តេវាសិកដ្ឋាន	៤៦
សរុប	**៤០១**

តារាងទី១ បង្ហាញថាមានមណ្ឌលចំនួន ៤០១ ផ្តល់ការថែទាំដល់កុមារក្នុងរាជធានីខេត្តគោលដៅទាំង៥។ មានមណ្ឌលថែទាំកុមារចំនួន ២៦៧ កន្លែងស្នាក់នៅបណ្តោះអាសន្នចំនួន ២០ ផ្ទះរស់នៅជាក្រុមចំនួន ៥៧ វត្តអារាម និងអគារសាសនាចំនួន ១១ ព្រមទាំអន្តេវាសិកដ្ឋានចំនួន ៤៦។ តារាងបានបង្ហាញឱ្យឃើញថាមណ្ឌលភាគច្រើន គឺជាមណ្ឌលថែទាំកុមារដែលមានលក្ខខណ្ឌស្របទៅនឹងនិយមន័យរបស់មណ្ឌលត្រូវបានរៀបចំឡើងដើម្បីផ្តល់សេវាជូនកុមារដែលត្រូវបានបោះបង់ ឬមិនអាចរស់នៅជាមួយគ្រួសារបង្កើត និងសាច់ញាតិរបស់ពួកគេនៅក្នុងសហគមន៍។

៥.២ ទិន្នន័យអំពីមណ្ឌលថែទាំកុមារ

តារាងទី២ ៖ ចំនួនមណ្ឌលថែទាំកុមារដែលគេដឹងមុនពេលកំណត់ទីតាំង

មណ្ឌលថែទាំកុមារដែលគេដឹង ផ្អែកលើអធិការកិច្ចរបស់ក្រសួង ក្នុងឆ្នាំ២០១៤	មណ្ឌលថែទាំកុមារដែលត្រូវបាន កំណត់រកឃើញក្នុងអំឡុងពេល ធ្វើការកំណត់ទីតាំង	ចំនួនមណ្ឌលដែលកើនឡើង
១៣៩	២៦៧	៩២%

តារាងទី២ បង្ហាញថាមានមណ្ឌលថែទាំកុមារចំនួន១៣៩ ដែលក្រសួងដឹង និងត្រូវបានធ្វើអធិការកិច្ច ក្នុងឆ្នាំ២០១៤[6] ដោយឡែកការកំណត់ទីតាំងបានរកឃើញមណ្ឌលថែទាំកុមារសរុបចំនួន ២៦៧ មានការកើនឡើងចំនួន ៩២%។ កត្តានេះភាគច្រើនគឺបាន មកពីការធ្វើអធិការកិច្ចលើមណ្ឌលថែទាំកុមារដែលមានកិច្ចព្រមព្រៀងជាមួយក្រសួងប៉ុណ្ណោះ។ តារាងនេះបង្ហាញថាចំនួនមណ្ឌលថែទាំកុមារ មានការកើនឡើងស្ទើរទ្វេដង បើធៀបទៅនឹងចំនួនដែលមានកន្លងមក។ របកគំហើញនេះបានឱ្យដឹងថា កុមារប្រមាណពាក់កណ្តាលដែលរស់នៅក្នុងមណ្ឌលថែទាំក្នុងរាជធានីខេត្តគោលដៅទាំងប្រាំកំពុងរស់នៅក្នុងមណ្ឌលដែលពុំមានការធ្វើនិយ័តកម្ម។

តារាងទី៣ ៖ មណ្ឌលថែទាំកុមារដែលផ្តល់ការថែទាំរយៈពេលខ្លី និងរយៈពេលវែង

ប្រភេទមណ្ឌល	ចំនួន	ភាគរយ
មណ្ឌលថែទាំកុមារ ដែលផ្តល់ការថែទាំរយៈពេលខ្លី (តិចជាង ៦ខែ)	២៣	៩
មណ្ឌលថែទាំកុមារ ដែលផ្តល់ការថែទាំ រយៈពេលវែង (ច្រើនជាង ៦ខែ)	១៧៣	៦៥
មណ្ឌលថែទាំកុមារ ដែលពុំមានកំណត់ រយៈពេលផ្តល់ការថែទាំ	៧១	២៦
សរុប	**២៦៧**	**១០០**

តារាងទី៣ បង្ហាញថាមណ្ឌលចំនួន ២៦៧ ដែលអាចកំណត់ថាជាមណ្ឌលថែទាំកុមារ ត្រូវបានរៀបចំឡើង ដើម្បីផ្តល់សេវាជូនកុមារកំព្រា ឬកុមារត្រូវបានបោះបង់ចោល ឬ កុមារដែលមិនអាចរស់នៅជាមួយគ្រួសារបង្កើត និងសាច់ញាតិរបស់ពួកគេនៅក្នុងសហគមន៍។ ក្នុងចំណោមមណ្ឌលទាំង ២៦៧ មានមណ្ឌលចំនួន ១៧៣ (៦៥%) ដែលផ្តល់ការថែទាំរយៈពេលវែង (ច្រើនជាង៦ខែ) និង មណ្ឌលចំនួន ២៣ (៩%) ដែលផ្តល់ការថែទាំរយៈពេលខ្លី (តិចជាង ៦ខែ)។ មានមណ្ឌលចំនួន ៧១ (២៦%) ដែលពុំមានទិន្នន័យអំពីរយៈពេល ដែលអនុញ្ញាតឱ្យស្នាក់នៅ។ តារាងបង្ហាញឱ្យដឹងថា មណ្ឌលថែទាំកុមារភាគច្រើនផ្តល់ការថែទាំរយៈពេលវែង។ ទិន្នន័យនេះមានសារៈសំខាន់ក្នុងការកត់សម្គាល់ថា គោលការណ៍ណែនាំស្តីពីការថែទាំជំនួសចំពោះកុមារ[7] និងគោលនយោបាយស្តីពីការថែទាំជំនួសចំពោះកុមារ[8] បានចែងយ៉ាងច្បាស់ថាមណ្ឌលថែទាំកុមារគប្បីជាជម្រើសចុងក្រោយ និងជាដំណោះស្រាយបណ្តោះអាសន្ន ហើយការថែទាំនៅក្នុងគ្រួសារ និងសហគមន៍គឺជាជម្រើសប្រសើរបំផុតសម្រាប់ការថែទាំកុមារ។

តារាងទី៤ ៖ ចំនួនកុមារដែលរស់នៅក្នុងមណ្ឌល យោងតាមសេចក្តីរាយការណ៍របស់មណ្ឌល

កុមារ	ចំនួន	ភាគរយ
កុមារា	៦.១៨១	៥២
កុមារី	៥.៦០៧	៤៨
សរុប	**១១.៧៨៨**	**១០០**

[6] *របាយការណ៍អធិការកិច្ចរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងមូលដ្ឋានទិន្នន័យអំពីការថែទាំជំនួស។*

[7] *សេចក្តីថ្លែងការណ៍ដែលអនុម័តដោយមហាសន្និបាតអង្គការសហប្រជាជាតិ ក្នុងខែកុម្ភៈ ឆ្នាំ២០១០ ទំព័រ៤ ចំណុច១៤។*

[8] *គោលនយោបាយស្តីពីការថែទាំជំនួសចំពោះកុមារ រាជរដ្ឋាភិបាលកម្ពុជា ខែមេសា ឆ្នាំ២០០៦ ជំពូក៤ ទំព័រ១២។*

តារាងទី៤ បង្ហាញថាមានកុមារចំនួន ១១.៧៨៨នាក់ កំពុងរស់នៅក្នុងមណ្ឌលថែទាំកុមារ ក្នុងរាជធានីខេត្តគោលដៅទាំងប្រាំ។ ក្នុងចំណោមកុមារសរុបមានកុមារាចំនួន៦.១៨១នាក់(៥២%) និងកុមារីចំនួន៥.៦០៧នាក់ (៤៨%)។ ទិន្នន័យនេះមានសារៈសំខាន់ក្នុងការកត់សម្គាល់ថា ព័ត៌មានត្រូវបានរាយការណ៍ឱ្យដឹងដោយអ្នកដែលទទួលខុសត្រូវគ្រប់គ្រងលើមណ្ឌលថែទាំកុមារទាំង ២៦៧ និងមិនមែនផ្អែកលើការរាប់ចំនួនកុមារដែលរស់នៅក្នុងមណ្ឌលដោយផ្ទាល់នោះទេ។ របាយការណ៍អធិការកិច្ចដែលធ្វើឡើងដោយក្រសួងបានរកឃើញថាមានកុមារចំនួន ៧.៥៤៥នាក់។ ទិន្នន័យនេះបានឱ្យដឹងថាកុមារដែលកំពុងរស់នៅក្នុងមណ្ឌលមានចំនួនច្រើនជាងចំនួនកុមារ ដែលត្រូវបានប៉ាន់ប្រមាណកាលពីមុនរហូតដល់ ៦៤% ប្រសិនបើគេពិនិត្យមើលទៅលើព័ត៌មានដូចមានបញ្ជាក់ខាងលើ។

តារាងទី៥ ៖ ស្ថានភាពនៃការចុះបញ្ជីមណ្ឌលថែទាំកុមារ

ប្រភេទមណ្ឌល	ចំនួន	ភាគរយ
ចុះបញ្ជី ជាមួយក្រសួងមហាផ្ទៃ	១៥២	៥៧
ចុះបញ្ជី ជាមួយក្រសួងការបរទេស	៤៨	១៨
ចុះបញ្ជី ជាមួយក្រសួងមហាផ្ទៃ និងក្រសួងការបរទេស	១៤	៥
ចុះបញ្ជី ជាមួយអាជ្ញាធរមូលដ្ឋាន	៧	៣
មណ្ឌលកុមារកំព្រារដ្ឋ (មិនតម្រូវឱ្យចុះបញ្ជី)	៩	៣
មណ្ឌលដែលមិនបានចុះបញ្ជី	៣៧	១៤
សរុប	**២៦៧**	**១០០**

តារាងទី៥ បង្ហាញថាមានមណ្ឌលថែទាំកុមារចំនួន ១៥២ ដែលចុះបញ្ជីជាមួយក្រសួងមហាផ្ទៃ មណ្ឌលចំនួន ៤៨ ចុះបញ្ជីជាមួយក្រសួងការបរទេស មណ្ឌលចំនួន ១៤ ចុះបញ្ជីជាមួយក្រសួងមហាផ្ទៃ និងក្រសួងការបរទេស និងមណ្ឌលចំនួន ៧ ចុះបញ្ជីជាមួយអាជ្ញាធរមូលដ្ឋាន។ ក្នុងនោះក៏មានមណ្ឌលរដ្ឋចំនួន ៩ ផងដែរ ដែលមិនតម្រូវឱ្យចុះបញ្ជី។ មណ្ឌលដែលមិនបានចុះបញ្ជីមានចំនួន ៣៧មណ្ឌល។ តារាងនេះ បង្ហាញឱ្យដឹងថាមណ្ឌលថែទាំកុមារចំនួន ៨៦% (រាប់បញ្ចូលមណ្ឌលកុមារកំព្រារដ្ឋទាំង ៩) បានចុះបញ្ជី និង១៤% មិនបានចុះបញ្ជី។

តារាងទី៦ ៖ មណ្ឌលថែទាំកុមារដែលមានអនុស្សរណៈនៃការយោគយល់ជាមួយទីភ្នាក់ងាររដ្ឋាភិបាល

ប្រភេទមណ្ឌល	ចំនួន	ភាគរយ
មណ្ឌលដែលមាន អនុស្សរណៈនៃការយោគយល់ចំនួនមួយ ឬច្រើនជាងនេះ	១៧៤	៦៥
មណ្ឌលដែលពុំមាន អនុស្សរណៈនៃការយោគយល់	៨៤	៣២
មណ្ឌលកុមារកំព្រារដ្ឋ (មិនតម្រូវឱ្យចុះបញ្ជី)	៩	៣
សរុប	**២៦៧**	**១០០**

តារាងទី៦ បង្ហាញថាមណ្ឌលថែទាំកុមារចំនួន ១៧៤ (មិនរាប់បញ្ចូលមណ្ឌលកុមារកំព្រារដ្ឋដែលមិនតម្រូវឱ្យ មានអនុស្សរណៈនៃការយោគយល់) មានអនុស្សរណៈនៃការយោគយល់ចំនួនមួយ ឬ ច្រើន ជាមួយក្រសួង មួយ និង មណ្ឌលចំនួន ៨៤ ពុំមានអនុស្សរណៈនៃការយោគយល់ឡើយ។ តារាងនេះបង្ហាញឱ្យដឹងថាមានមណ្ឌល១ក្នុងចំណោមមណ្ឌលចំនួន៣ ធ្វើប្រតិបត្តិការដោយគ្មានកិច្ចព្រមព្រៀងផ្លូវការ។ មណ្ឌលថែទាំកុមារសរុបចំនួន ១៤៤ (៥៤%) មានអនុស្សរណៈនៃការយោគយល់មួយជាមួយក្រសួង។

តារាងទី៧ ៖ ចំនួនមណ្ឌលថែទាំកុមារ បែងចែកទៅតាមរាជធានី/ខេត្ត

រាជធានី/ខេត្ត	ចំនួន	ភាគរយ
ភ្នំពេញ	១១៧	៤៤
សៀមរាប	៨០	៣០
បាត់ដំបង	៣៥	១៣
កណ្តាល	២០	៧
ព្រះសីហនុ	១៥	៦
សរុប	**២៦៧**	**១០០**

តារាងទី៧ បង្ហាញថាមានមណ្ឌលថែទាំកុមារចំនួន ១១៧ នៅរាជធានីភ្នំពេញ ៨០ នៅខេត្តសៀមរាប ៣៥ នៅខេត្តបាត់ដំបង ២០ នៅខេត្តកណ្តាល និង ១៥ នៅខេត្តព្រះសីហនុ។ តារាងនេះបង្ហាញឱ្យដឹងថា មណ្ឌល ភាគច្រើនស្ថិតនៅរាជធានីភ្នំពេញ (៤៤%) និង ខេត្តសៀមរាប (៣០%)។

៥.៣ ទិន្នន័យពីប្រភេទទីកន្លែងផ្តល់ការថែទាំសម្រាប់កុមារ និងយុវជនមានអាយុលើស ១៨ ឆ្នាំ

៥.៣.១ ទិន្នន័យអំពីផ្ទះស្នាក់នៅបណ្តោះអាសន្ន

តារាងទី៨ ៖ ចំនួនកន្លែងស្នាក់នៅបណ្តោះអាសន្ននិងចំនួនកុមារ ដែលរស់នៅ ទីនោះ

រាជធានី/ខេត្ត	ចំនួនផ្ទះបណ្តោះអាសន្ន	ចំនួនកុមារ		
		កុមារី	កុមារា	សរុប
ភ្នំពេញ	១៤	២២៤	១០៨	៣៣២
សៀមរាប	១	៦	១០	១៦
បាត់ដំបង	០	០	០	០
កណ្តាល	២	១០	១៩	២៩
ព្រះសីហនុ	៣	៣០១	២៧៣	៥៧៤
សរុប	**២០**	**៥៤១**	**៤១០**	**៩៥១**

តារាងទី៨ បង្ហាញថាមានកន្លែងស្នាក់នៅបណ្តោះអាសន្នចំនួន២០។ ទាំងនេះ គឺជាទម្រង់មួយនៃការថែទាំក្នុងមណ្ឌលដែលមានកំណត់រយៈពេលស្នាក់នៅសម្រាប់កុមារ ដែលកំពុងស្ថិតនៅក្នុងដំណើរការរៀបចំផែនការគ្រួសារអចិន្ត្រៃយ៍ ឬចំពោះកុមារដែលគ្រួសាររបស់ពួកគេកំពុងជួបប្រទះ វិបត្តិធ្ងន់ធ្ងរ និងទាមទារឱ្យមានលំនៅដ្ឋានបណ្តោះអាសន្នសម្រាប់កូនពួកគេ ដើម្បីឱ្យបរិយាកាសគ្រួសារមានស្ថេរភាព។ មានផ្ទះបណ្តោះអាសន្នចំនួន ១៤ នៅរាជធានីភ្នំពេញ ៣ នៅខេត្តព្រះសីហនុ ២ នៅខេត្តកណ្តាល និង ១ នៅខេត្តសៀមរាប។ តារាងនេះបង្ហាញឱ្យដឹងថា ផ្ទះបណ្តោះអាសន្នភាគច្រើនស្ថិតនៅ រាជធានីភ្នំពេញ ប៉ុន្តែចំនួនកុមារភាគច្រើនដែលរស់នៅក្នុងផ្ទះបណ្តោះអាសន្ន គឺស្ថិតនៅក្នុងខេត្ត ព្រះសីហនុ។ កុមារភាគច្រើននៅក្នុងមណ្ឌលទាំងនេះគឺជាកុមារី (៥៧%)។

តារាងទី៩ ៖ ចំនួនផ្ទះរស់នៅជាក្រុម និងចំនួនកុមារដែលរស់នៅទីនោះ

រាជធានី/ខេត្ត	ចំនួនផ្ទះរស់នៅជាក្រុម	ចំនួនកុមារ		
		កុមារី	កុមារា	សរុប
ភ្នំពេញ	១៧	២៤៣	១៧៩	៤២២
សៀមរាប	១៤	៧៩	៦១	១៤០
បាត់ដំបង	១៩	៥៤	៧២	១២៦
កណ្ដាល	៥	៨៥	៧១	១៥៦
ព្រះសីហនុ	២	២០១	២៤៧	៤៤៨
សរុប	**៥៧**	**៦៦២**	**៦៣០**	**១.២៩២**

តារាងទី៩ បង្ហាញថាមានផ្ទះរស់នៅជាក្រុមចំនួន ៥៧ ដែលត្រូវបានរាយការណ៍ឱ្យដឹងថាកំពុងផ្ដល់ការ ថែទាំជំនួសដល់កុមារសរុបចំនួន ១.២៩២នាក់ រាប់បញ្ចូលកុមារីចំនួន ៦៦២នាក់។ ផ្ទះរស់នៅជាក្រុម គឺជាការថែទាំដែលផ្ដល់ជូនដល់កុមារក្នុងចំនួនមួយមានកម្រិត នៅក្នុងបរិយាកាសគ្រួសារ ក្រោមការគ្រប់គ្រង ត្រួតពិនិត្យរបស់អ្នកថែទាំមួយក្រុមតូចដែលពុំមែនជាសាច់ញាតិជាមួយកុមារ។ មានផ្ទះរស់នៅជាក្រុមចំនួន១៩ នៅខេត្តបាត់ដំបង ១៧ នៅរាជធានីភ្នំពេញ ១៤ នៅខេត្តសៀមរាប ៥ នៅខេត្តកណ្ដាល និង ២ នៅខេត្តព្រះសីហនុ។ តារាងនេះបង្ហាញឱ្យដឹងថាផ្ទះរស់នៅជាក្រុមភាគច្រើន ស្ថិតនៅក្នុងខេត្តបាត់ដំបង ដែលផ្ដល់ការថែទាំជូនកុមារសរុបចំនួន ១២៦នាក់។ បើទោះជាដូច្នេះក្ដី កុមារភាគច្រើនដែលរស់នៅក្នុងផ្ទះស្នាក់នៅជាក្រុម កំពុងរស់នៅក្នុងផ្ទះស្នាក់នៅជាក្រុមចំនួន២ ក្នុងខេត្តព្រះសីហនុ ដែលមានកុមារចំនួន ៤៤៨នាក់។

តារាងទី១០ ៖ ចំនួនអន្ដេវាសិកដ្ឋាន និងចំនួនកុមារដែលរស់នៅទីនោះ

រាជធានី/ខេត្ត	ចំនួនអន្ដេវាសិកដ្ឋាន	ចំនួនកុមារ		
		កុមារី	កុមារា	សរុប
ភ្នំពេញ	២២	១.១៧៩	១.036	២.២១៥
សៀមរាប	១៦	៥៣៩	៧៦៨	១.៣០៧
បាត់ដំបង	៣	៤	១០១	១០៥
កណ្ដាល	៤	៣៩	៩១	១៣០
ព្រះសីហនុ	១	១០៣	១២៨	២៣១
សរុប	**៤៦**	**១.៨៦៤**	**២.១២៤**	**៣.៩៨៨**

តារាងទី១០ បង្ហាញថាមានអន្ដេវាសិកដ្ឋានសរុបចំនួន ៤៦ ផ្ដល់ការថែទាំដល់កុមារ ចំនួន ៣.៩៨៨នាក់ ដែលរួមមានកុមារីចំនួន ១.៨៦៤នាក់។ មានអន្ដេវាសិកដ្ឋានចំនួន ២២ នៅរាជធានីភ្នំពេញ ១៦ នៅខេត្តសៀមរាប ៤ នៅខេត្តកណ្ដាល ៣ នៅខេត្តបាត់ដំបង និង ១ នៅខេត្ត ព្រះសីហនុ។ តារាងនេះបង្ហាញឱ្យដឹងថាអន្ដេវាសិកដ្ឋានភាគច្រើន ស្ថិតនៅរាជធានីភ្នំពេញ និងខេត្តសៀមរាប។ បើនិយាយតាមបច្ចេកទេស អន្ដេវាសិកដ្ឋានត្រូវបានកំណត់និយមន័យថាជាការរៀបចំលំនៅដ្ឋានសម្រាប់ឱ្យកុមារស្នាក់នៅក្នុងរយៈពេលនៃការសិក្សារបស់ពួកគេ។ អន្ដេវាសិកដ្ឋានត្រូវបានបញ្ចូលនៅក្នុងការកំណត់ទីតាំងមណ្ឌល ដោយសារតែមានការព្រួយបារម្ភថាសាលារៀនមួយចំនួនក្នុងចំណោមសាលារៀនទាំងនេះ អាចជាមណ្ឌលថែទាំកុមារ ដែលក្លែងបន្លំជាអន្ដេវាសិកដ្ឋានដើម្បីជៀសវាងការធ្វើអធិការកិច្ច និងការដែលត្រូវអនុវត្តស្របតាមក្របខ័ណ្ឌនិយ័តកម្មដែលបានកំណត់។

៥.៣.២ ការថែទាំតាមវត្តអារាម និងអគារសាសនា

ការថែទាំតាមវត្តអារាម និងកន្លែងសាសនា គឺជាការថែទាំដែលផ្តល់ជូនកុមារ ដោយព្រះសង្ឃ ដូនជី អាចារ្យ និង អង្គភាពសាសនានានាដែលផ្តល់ឱ្យកុមារនូវសេចក្តីត្រូវការមូលដ្ឋានរបស់ពួកគេ នៅក្នុងវត្ត និងកន្លែងសាសនាដទៃទៀត។ ការកំណត់ទីតាំងមណ្ឌលនេះ បានរកឃើញវត្តអារាម និងកន្លែងសាសនា ដទៃទៀត សរុបចំនួន ១១ ដែលបានរាយការណ៍ឱ្យដឹងថា កំពុងផ្តល់ការថែទាំជូនកុមារចំនួន៩៣២នាក់ ដែលរួមមានកុមារីចំនួន ២៥៩នាក់។ មានវត្តអារាម និងកន្លែងសាសនាដទៃទៀតដែលផ្តល់ការថែទាំកុមារ ចន្លោះពី ២ ទៅ ៩ ក្នុងរាជធានីខេត្តនីមួយៗក្នុងចំណោមរាជធានី ខេត្តគោលដៅទាំងប្រាំ។

៥.៣.៣ យុវជនដែលរស់នៅក្នុងមណ្ឌល ថែទាំកុមារ

ការកំណត់ទីតាំងមណ្ឌលបានរកឃើញថា មានយុវជនចំនួន ៧.៧០៨នាក់ ដែលរួមមានយុវនារីចំនួន ២.៧១៧ នាក់ កំពុងរស់នៅក្នុងមណ្ឌលថែទាំកុមារ។ ពួកគេភាគច្រើន (៥.៧០៦នាក់ រាប់បញ្ចូលយុវនារីចំនួន ១.៦៥៥នាក់) កំពុងរស់នៅក្នុងមណ្ឌលថែទាំកុមារ ជាពិសេសគឺនៅក្នុងរាជធានីភ្នំពេញ។ ក្នុងចំណោមចំនួនសរុបនេះ មានយុវជនចំនួន ១.០៣០នាក់ រាប់បញ្ចូលយុវនារីចំនួន ៥៨៨នាក់ កំពុងរស់នៅក្នុងអន្តេវាសិកដ្ឋាន។

6.0 សេចក្តីសន្និដ្ឋាន

ការកំណត់ទីតាំងមណ្ឌលបច្ចុប្បន្ននេះ ត្រូវបានធ្វើឡើងដើម្បីរាប់ និងចងក្រងឯកសារអំពីចំនួនមណ្ឌលដែលផ្តល់ការថែទាំជំនួសចំពោះកុមារ នៅរាជធានីភ្នំពេញ ខេត្តសៀមរាប ខេត្តបាត់ដំបង ខេត្តព្រះសីហនុ និង ខេត្តកណ្តាល។ ការកំណត់ទីតាំងនេះ បានរកឃើញថា មានកន្លែងថែទាំកុមារសរុបចំនួន ៤០១ មណ្ឌល កំពុងផ្តល់ការថែទាំដល់កុមារនៅក្នុងរាជធានីខេត្តគោលដៅទាំងប្រាំ។ មានមណ្ឌលថែទាំកុមារចំនួន ២៦៧ ដែលមានកុមារចំនួន ១១.៧៨៨ នាក់ (៦.១៨១នាក់ ជាកុមារា និង ៥.៦០៧នាក់ ជាកុមារី) កំពុងរស់នៅ បើធៀបទៅនឹងតួលេខមណ្ឌលថែទាំកុមារចំនួន១៣៩ មានកុមារចំនួន ៧.៥៤៥នាក់ ដែលក្រសួងបានដឹង និងបានធ្វើអធិការកិច្ចក្នុងឆ្នាំ២០១៤។ មណ្ឌលដទៃទៀតដែលកំពុងផ្តល់ការថែទាំជូនកុមារ និងដែលត្រូវបានកំណត់រកឃើញផងដែរ ក្នុងអំឡុងពេលនៃការធ្វើការកំណត់ទីតាំងមណ្ឌលរួមមាន៖ មណ្ឌលចំនួន ២០ ដែលផ្តល់ការថែទាំបណ្តោះអាសន្ន (មានកុមារចំនួន ៩៥១នាក់ រាប់បញ្ចូលកុមារីចំនួន ៥៤១នាក់) ផ្ទះរស់នៅជាក្រុមចំនួន ៥៧ (មានកុមារចំនួន ១.២៩២នាក់ រាប់បញ្ចូលកុមារីចំនួន ៦៦២នាក់) វត្តអារាម និងកន្លែងសាសនាដទៃទៀតដែលផ្តល់ការថែទាំដល់កុមារ (មានកុមារចំនួន ៤៣២នាក់ រាប់បញ្ចូលកុមារីចំនួន ២៥៩នាក់) និង អន្តេវាសិកដ្ឋានចំនួន ៤៦ (មានកុមារចំនួន ៣.៩៨៨នាក់ រាប់បញ្ចូល កុមារីចំនួន ១.៨៦៤នាក់)។ តាមរបាយការណ៍ឱ្យដឹងថាមានយុវជនចំនួន ៧.៧០៨នាក់ ផងដែរ (យុវជនចំនួន ៤.៩៩១នាក់ និងយុវនារីចំនួន ២.៧១៧នាក់) កំពុងរស់នៅក្នុងមណ្ឌលទាំងនេះ។ បើយោងតាមរបាយការណ៍នៃការកំណត់ទីតាំងនេះមានមណ្ឌលថែទាំកុមារចំនួន ១៤% ក្នុងចំណោមមណ្ឌលចំនួន ២៦៧ មិនទាន់បានចុះបញ្ជី និង ៣២% ពុំមានអនុស្សរណៈនៃការយោគយល់ជាមួយក្រសួងណាឡើយ។ មណ្ឌលភាគច្រើន(៦៥%)កំពុងផ្តល់សេវារយៈពេលវែង។

របកគំហើញបឋមពីការកំណត់ទីតាំងមណ្ឌលបច្ចុប្បន្ននេះ គប្បីយកមកពិចារណាដើម្បីវិភាគបន្ថែមទៀតទៅលើស្ថានភាពរបស់កុមារដែលកំពុងរស់នៅក្នុងមណ្ឌល និងចាត់វិធានការជាក់ស្តែងដើម្បីសមាហរណកម្មចំនួនកុមារដែលកំពុងរស់នៅក្នុងមណ្ឌលដោយមិនចាំបាច់ ដែលធ្វើឱ្យពួកគេបាត់បង់សេចក្តីស្រឡាញ់ និងបរិយាកាសគ្រួសារដែលមានសុវត្ថិភាព និងផ្តល់កិច្ចការពារដល់ពួកគេ។ ឥឡូវនេះ ក្រសួងបានបញ្ចប់ការកំណត់ទីតាំងមណ្ឌលនៅក្នុងខេត្តដទៃទៀត។ របាយការណ៍ទាំងស្រុងអំពីការកំណត់ទីតាំងមណ្ឌលនៅក្នុងគ្រប់រាជធានី ខេត្តទាំងអស់នឹងត្រូវបានបោះពុម្ពផ្សាយនៅពាក់កណ្តាលឆ្នាំ២០១៦។ ការរកឃើញនេះស្របជាមួយនឹងការរកឃើញដោយវិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ សកលវិទ្យាល័យកុឡុំប៊ែរ និងការវិភាគទិន្នន័យតាមរយៈទម្រង់សម្រង់ព័ត៌មានអំពីមណ្ឌលថែទាំកុមារនឹងផ្តល់ទិន្នន័យបន្ថែមស្តីពីកុមារកំពុងរស់នៅក្នុងមណ្ឌលថែទាំ។

ការថែទាំតាមមណ្ឌលគប្បីចាត់ទុកថាជាជម្រើសចុងក្រោយ និងសម្រាប់រយៈពេលខ្លីប៉ុណ្ណោះ យោងតាមបទដ្ឋានអន្តរជាតិ និងគោលនយោបាយព្រមទាំងលិខិតបទដ្ឋានគតិយុត្តិស្តីពីការថែទាំជំនួសដែលអនុម័តដោយរាជរដ្ឋាភិបាលកម្ពុជា។ កុមារ និងយុវជនគ្រប់រូប គួររស់នៅក្នុងបរិយាកាសមួយដែលផ្តល់កិច្ចគាំទ្រ កិច្ចការពារ និងការថែទាំ ដែលលើកកម្ពស់សក្តានុពលពេញលេញដល់ពួកគេ។ អាស្រ័យដោយគេដឹងថាកុមារភាគច្រើនដែលរស់នៅក្នុងមណ្ឌលពុំមែនជាកុមារកំព្រា ដូច្នេះគេចាំបាច់ត្រូវលើកកម្ពស់ការថែទាំតាមគ្រួសារ និងសហគមន៍ដល់ពួកគេ ដើម្បីធានាឱ្យបាននូវសុវត្ថិភាព កិច្ចការពារ និងសុខុមាលភាពរបស់ពួកគេ។ ការអនុម័តនាពេលថ្មីៗនេះទៅលើអនុក្រឹត្យស្តីពីការគ្រប់គ្រងមណ្ឌលថែទាំកុមារក្នុងប្រទេសកម្ពុជា គឺជាសមិទ្ធផលមួយដ៏សំខាន់ឆ្ពោះទៅរកការគោរពបទដ្ឋានថែទាំជំនួស និងកិច្ចការពារកុមារ។ ក្រសួងសូមបញ្ជាក់ឡើងវិញនូវការចូលរួមរបស់ក្រសួង សំដៅលើកកម្ពស់ការថែទាំតាមគ្រួសារ និងសហគមន៍ និងបង្ការការយកកុមារទៅដាក់ក្នុងមណ្ឌល ដោយមិនមានភាពចាំបាច់។ ដើម្បីសម្រេចឱ្យបាននូវគោលដៅនេះ និងធានាបាននូវការអនុវត្តន៍ក្របខ័ណ្ឌថែទាំជំនួសដែលមានស្រាប់ ក្រសួងប្តេជ្ញាសមាហរណកម្មកុមារដែលរស់នៅក្នុងមណ្ឌលចំនួន ៣០% និងបង្ការកុមារទាំងឡាយណាអាយុក្រោម ៣ឆ្នាំ ពីការយកទៅទុកដាក់នៅក្នុងមណ្ឌលឱ្យបានត្រឹមឆ្នាំ២០១៨។

ឧបសម្ព័ន្ធ១: និយមន័យ

ដើម្បីធ្វើការអង្កេតនេះ និយមន័យដូចខាងក្រោមត្រូវបានយកមកពីចារណា:

- **មណ្ឌលថែទាំកុមារ**: គឺជាមណ្ឌលដែលផ្តល់សេវាជូនកុមារត្រូវបានគេបោះបង់ចោល ឬ កុមារដែលមិនអាចរស់នៅជាមួយគ្រួសារបង្កើត និងសាច់ញាតិរបស់ពួកគេនៅក្នុងសហគមន៍បាន។
- **កន្លែងស្នាក់នៅបណ្តោះអាសន្ននឹងកន្លែងទទួលកុមារជាបន្ទាន់**: គឺជាទម្រង់មួយនៃការថែទាំកុមារនៅក្នុងមណ្ឌលដែលមានរយៈពេលកំណត់ ដើម្បីធ្វើផែនការទុកដាក់កុមារជាអចិន្ត្រៃយ៍ ឬសម្រាប់គ្រួសារជួបវិបត្តិធ្ងន់ធ្ងរ ហើយតម្រូវឲ្យកុមារស្នាក់នៅបណ្តោះអាសន្ន រងចាំពេលគ្រួសារពួកគេមានបរិយាកាសល្អឡើងវិញ។
- **ផ្ទះរស់នៅជាក្រុម**: គឺជាការថែទាំកុមារដែលផ្តល់ជូនដល់កុមារក្នុងចំនួនមួយមានកម្រិត នៅក្នុងបរិយាកាសគ្រួសារក្រោមការគ្រប់គ្រង ត្រួតពិនិត្យរបស់អ្នកថែទាំមួយក្រុមតូច ដែលពុំជាប់សាច់ញាតិជាមួយគេ។
- **ការថែទាំតាមវត្តអារាម និងកន្លែងសាសនា**: គឺជាការថែទាំដែលផ្តល់ជូនកុមារ ដោយព្រះសង្ឃ ដូនជី អាចារ្យ និងអង្គភាពសាសនាដែលផ្តល់ឱ្យកុមារនូវសេចក្តីត្រូវការមូលដ្ឋានរបស់ពួកគេ នៅក្នុងវត្ត និងកន្លែងសាសនាដទៃទៀត។
- **អន្តេវាសិកដ្ឋាន/លំនៅដ្ឋានស្នាក់នៅដើម្បីការសិក្សា**: គឺជាការរៀបចំលំនៅដ្ឋានសម្រាប់ឱ្យកុមារស្នាក់នៅក្នុងរយៈពេលនៃការសិក្សាមួយវគ្គឬ ពីរវគ្គ ដោយសារផ្ទះរបស់ពួកគេនៅឆ្ងាយពីសាលា។

ចំនួន និងប្រភេទ
មណ្ឌលថែទាំជំនួសចំពោះកុមារ

ប្រភេទ	ចំនួន
មណ្ឌលថែទាំកុមារ	២៦៧
ផ្ទះស្នាក់នៅជាក្រុម	៥៧
កន្លែងស្នាក់នៅបណ្តោះអាសន្ន	២០
វត្តអារាម និង អគារសាសនា	១១
អន្តេវាសិកដ្ឋាន	៤៦

unicef
3PC Together, building stronger child protection systems
USAID FROM THE AMERICAN PEOPLE